# សុន្ទរកថាស្វាគមន៍ និងរបាយការណ៍
# របស់ឯកឧត្តម ខូយ រីដា អភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់
# ក្នុងសន្និសីទសារព័ត៌មានស្តីពីភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២)
# របស់រដ្ឋបាលខេត្តពោធិ៍សាត់
# ទីស្តីការគណៈរដ្ឋមន្ត្រី, ថ្ងៃទី៧ ខែ មីនា ឆ្នាំ ២០២៣

**សូមគោរព!**

- ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល *ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- ..........................................................................................................
- ឯកឧត្តម លោកជំទាវ លោក លោកស្រី *ជាទីគោរពរាប់អាន!*
- ..........................................................................................................

ថ្ងៃនេះក្នុងនាមរដ្ឋបាលខេត្តពោធិ៍សាត់ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយប្រកបដោយនក្ខត្តឫក្ស ដ៏វិសេសវិសាលថ្លៃថ្លាបំផុត ដែលរដ្ឋបាលខេត្តពោធិ៍សាត់ បានចូលរួមបង្ហាញពីភាពជោគជ័យ និងសមិទ្ធផលសំខាន់ៗ រយៈពេល ៥ឆ្នាំ (២០១៨-២០២២) ក្នុងសន្និសីទសារព័ត៌មាននាឱកាសនេះ។ ខ្ញុំសូមសម្តែងនូវការគោរពថ្លែងអំណរគុណចំពោះ ឯកឧត្តម ផៃ ស៊ីផាន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានចែករំលែកពេលវេលាដ៏មានតម្លៃ ដើម្បីដឹកនាំសម្របសម្រួលសន្និសីទសារព័ត៌មានដ៏មានសារសំខាន់នេះ។ ខ្ញុំសូមស្វាគមន៍ ចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអ្នកសារព័ត៌មានទាំងអស់ដែលបានអញ្ជើញចូលរួមប្រកបដោយមនោសញ្ចេតនាជ្រាលជ្រៅ និងភាពស្និទ្ធស្នាលយ៉ាងក្រៃលែង។

ឆ្លៀតក្នុងឱកាសដែលពោរពេញដោយមោទនភាពនេះ ខ្ញុំសូមអនុញ្ញាតជម្រាបជូន អំពីស្ថានភាពទូទៅ និងសមិទ្ធផលសំខាន់ៗដែលជាភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២) របស់ខេត្តពោធិ៍សាត់ ដូចខាងក្រោម៖

ខេត្តពោធិ៍សាត់ គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្ត ទាំង២៥ ស្ថិតនៅភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ ១៨៦ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ឆ្នាំង ខាងលិចជាប់នឹងខេត្តបាត់ដំបង និងប្រទេសថៃតាមខ្សែបន្ទាត់ព្រំដែនប្រវែងប្រមាណ ៨០គ.ម ខាងជើងជាប់នឹងខេត្តសៀមរាប និងខេត្តកំពង់ធំ ដែលលាតសន្ធឹងតាមបឹងទន្លេសាបប្រវែងប្រមាណ ៨៦គ.ម និងខាងត្បូងជាប់នឹងខេត្តកំពង់ស្ពឺ និងខេត្តកោះកុង។ រដ្ឋបាលដែនដី បែងចែកចេញជា ១រដ្ឋបាលក្រុង ៦រដ្ឋបាលស្រុក ៧សង្កាត់ ៤២ឃុំ និង៥២៦ភូមិ។ មានផ្លូវគមនាគមន៍សំខាន់ៗចំនួន៣ប្រភេទគឺ៖ ផ្លូវជាតិ មានចំនួន៥ខ្សែ ផ្លូវដែក ចំនួន១ខ្សែ និងផ្លូវទឹក បឹងទន្លេសាប។ មានប្រជាជនសរុបចំនួន **៥២០.៧៥២**នាក់ ស្រី **២៦៤.០៦៩**នាក់ ស្មើនឹង **១៣២.៨៥៥**គ្រួសារ។ ដង់ស៊ីតេប្រជាជនក្នុងខេត្តមានចំនួន ៤១នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ, អត្រាកំណើនប្រជាជនប្រចាំឆ្នាំ ១,៩៨%។ មានមុខ

បេដោមន្ត្រីរាជការ **៣,២០%** កសិករ **៧១,៦០%** សេវាករ **១៨,៧០%** ពាណិជ្ជករ **៥,៨០%** និងសិប្បករ **០,៧០%**។ ផលិតផលក្នុងស្រុកសរុប(GDP) សម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ មានចំនួន **១.៤៣៧** ដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១៨ មានការកើនឡើងចំនួន **១៦៦**ដុល្លារក្នុងម្នាក់។ ចំពោះអត្រាភាពក្រីក្របានធ្លាក់ចុះពី ១៦% នៅឆ្នាំ២០១៨ មកនៅត្រឹម ១២,៧០% នៅឆ្នាំ២០២២។ សណ្ឋានដីចែកជា ៤ប្រភេទ មានផ្ទៃដីសរុបទំហំ ១.២៦៩.២០០ ហិកតា ត្រូវបានបែងចែកជា៖

- -តំបន់ភ្នំ៖ មានផ្ទៃដីទំហំ **៨៥៦.៤៥៦** ហិកតា ស្មើនឹង **៦៧,៤៨%**
- -តំបន់ខ្ពង់រាប៖ មានផ្ទៃដីទំហំ **១៥៩.១៥៨** ហិកតា ស្មើនឹង **១២,៥៤%**
- -តំបន់ទំនាបកណ្ដាល៖ មានផ្ទៃដីទំហំ **១២៨.៩៥១** ហិកតា ស្មើនឹង **១០,១៦% និង**
- -តំបន់បឹងទន្លេសាប៖ មានផ្ទៃដីទំហំ **១២៤.៦៣៥** ហិកតា ស្មើនឹង **៩,៨២%** ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីគោរពមេត្រី!

ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ ក្រោមម្លប់នៃសុខសន្តិភាព និងក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ការដឹកនាំសម្របសម្រួលរបស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** និងដោយមានការឧបត្ថម្ភ គាំទ្រ ពីក្រសួង ស្ថាប័ន ពីក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានខេត្តពោធិ៍សាត់ ដែលមាន ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល, ឯកឧត្តម **កែវ រតនៈ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គនាយកអគ្គិសនីកម្ពុជា, ឯកឧត្តម នាយឧត្តមសេនីយ៍ **សែម សុវណ្ណនី**, ដៃគូអភិវឌ្ឍ, អង្គការ, សមាគម និងវិស័យឯកជន គួបផ្សំនឹងការច្នៃប្រឌិត សម្របសម្រួលជាមួយមន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ធ្វើឲ្យការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(២០១៩-២០២៣) និងផែនការអភិវឌ្ឍ៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិលប្រចាំឆ្នាំរបស់ខេត្តសម្រេចបានការងារសំខាន់ៗដូចខាងក្រោម៖

## ១.ការងាររដ្ឋបាល និងសន្តិសុខ

### ១.១.ការងារសន្តិសុខ សណ្តាប់ធ្នាប់

ជាទូទៅរដ្ឋបាលខេត្តយកចិត្តទុកដាក់ពង្រឹងគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្រុង ស្រុក និងអាជ្ញាធរឃុំ សង្កាត់ជាប្រចាំធ្វើឲ្យបទល្មើសគ្រប់ប្រភេទមានការថយចុះគួរឲ្យកត់សម្គាល់ ជាពិសេសបទល្មើសគ្រឿងញៀនថយចុះរហូតដល់១២០លើក។ លើការអនុវត្តការងារប្រឡងប្រណាំងគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ក្នុងចំណោម៤៩ឃុំ សង្កាត់ បានទទួលចំណាត់លេខ១ចំនួន ២៥ឃុំ សង្កាត់។ ជាមួយនេះ បានរៀបចំការពារសន្តិសុខ សុវត្ថិភាពជូនថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលអញ្ជើញមកបំពេញបេសកកម្មនៅលើទឹកដីខេត្តពោធិ៍សាត់បានយ៉ាងល្អប្រសើរ។

### ១.២.ការងារព្រំដែន និងសហប្រតិបត្តិការអន្តរជាតិ

អនុវត្តតាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃប្រទេសទាំង២ (កម្ពុជា-ថៃ) រដ្ឋបាលខេត្តបានយកចិត្តទុកដាក់ធ្វើកិច្ចសហប្រតិបត្តិការល្អជាមួយខេត្តត្រាត នៃព្រះរាជាណាចក្រថៃ ទាំងការងារសន្តិសុខ

តាមខ្សែបន្ទាត់ព្រំដែន ការទប់ស្កាត់បទល្មើសឆ្លងដែន និងជំងឺឆ្លងនានា។ ជាមួយនេះ ភាគីទាំង២តែងតែជួបប្រជុំថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់អង្គភាពជំនាញទៅតាមរបបប្រជុំយ៉ាងទៀតទាត់ សំដៅលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងការជំរុញការបើកច្រកទ្វារអន្តរជាតិព្រំដែនថ្មដា-បានថាសេនជាផ្លូវការឲ្យបានឆាប់។

## ១.៣.ការងារផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយ

យន្តការសម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋមាន ៣ថ្នាក់ ក្នុងគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព នៃការផ្តល់សេវារដ្ឋបាលលើវិស័យនានានៅកន្លែងតែមួយ។ ផ្អែកតាមស្មារតីនេះ រដ្ឋបាលខេត្តរៀបចំអគារអង្គភាពច្រកចេញចូលតែមួយខេត្ត ដែលផ្តល់សេវាលើ ១៤វិស័យ, ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុកទាំង៧ ដែលផ្តល់សេវាលើ ១៣ វិស័យ និងបានដាក់ឲ្យដំណើរការយន្តការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ នៅតាមសាលាឃុំ សង្កាត់ ទាំង ៤៩ក្នុងខេត្ត តាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ។ ការផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយ ត្រូវបានទទួលការគាំទ្រ និងសាទរពីប្រជាពលរដ្ឋដែលជាអ្នកមកស្នើសុំសេវា ដោយសាររាជរដ្ឋាភិបាលបានបង្វិតសេវាឲ្យកាន់តែកៀកជិតប្រជាពលរដ្ឋ ហើយនីតិវិធីមានលក្ខណៈសាមញ្ញ ឆាប់រហ័ស តម្លាភាព គណនេយ្យភាព ភាពជឿទុកចិត្តបាន និងគ្មានអំពើពុករលួយ។

## ១.៤.អំពីការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ

ក្នុងដំណើរការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ រដ្ឋបាលខេត្តប្រើប្រាស់វិធីសាស្ត្រដោះស្រាយជាចំហរផង មិនចំហរផង ជាឯកជនផង ជាការប្រមូលផ្តុំផង និងតាមប្រព័ន្ធទូរស័ព្ទ៣ខ្សែផង។

ជាលទ្ធផលគិតមកដល់ពេលនេះ រដ្ឋបាលខេត្ត បានសម្របសម្រួល ដោះស្រាយពាក្យបណ្តឹង បញ្ហាប្រឈម សំណូមពរ និងវិវាទផ្សេងៗជូនប្រជាពលរដ្ឋបានសរុបចំនួន ៦,៨៦៧ករណី និងតាមរយៈគណៈកម្មការសុរិយោដីមានវិវាទសរុបចំនួន ៦០ករណី បានបញ្ចប់ចំនួន ១៩ករណី ច្រានចោលចំនួន ១៣ករណី ដកពាក្យបណ្តឹងចំនួន ២០ករណី និងកំពុងដោះស្រាយ ០៨ករណី។

# ២-សមិទ្ធផលដែលអនុវត្តដោយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

## ២.១.ថវិកាគុណប្រយោជន៍រដ្ឋបាលខេត្ត

ក្នុងរយៈពេល៥ឆ្នាំនេះ រដ្ឋបាលខេត្តពោធិ៍សាត់ ទទួលចំណូលសរុបចំនួន (**មួយរយហុកសិបបីលាន បីរយចិតសិបពីរលាន ប្រាំមួយរយពីរពាន់ មួយរយសាមសិបបួនរៀលគត់**) ហើយបានចំណាយលើការងារអភិវឌ្ឍចំនួន (**មួយរយសែសិបពីរប៊ីលាន មួយរយសាមសិបបួនលាន ប្រាំរយហាសិបប្រាំពាន់ ប្រាំបីរយប៉ែតសិបប្រាំបួនរៀលគត់**) ទទួលបាននូវសមិទ្ធផលដូចខាងក្រោម៖

- សាងសង់អគារសាលាមត្តេយ្យ និងបឋមសិក្សា **ហ៊ុន សែន អ៊ុម អៀម** ០១ខ្នង ស្មើនឹង ៦បន្ទប់
- សាងសង់វេទិកាសម្រាប់រៀបចំពិធីបុណ្យអុំទូក, សាងសង់អគាររដ្ឋបាលសាលាខេត្ត, សាងសង់អគាររដ្ឋបាលឃុំ សង្កាត់បានចំនួន ៣សង្កាត់ និង ១១ឃុំ
- សាងសង់អគារការិយាល័យច្រកចេញចូលតែមួយបានចំនួន ៥ស្រុក
- ជួសជុលអគារអង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត និងធ្វើពិធីសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការ អង្គភាពច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ជាតំណាងទូទាំង

២៥ រាជធានី ខេត្ត កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- ជួសជុលផ្លូវចាក់កៅស៊ូ DBST ចំនួន ៦ខ្សែ ប្រវែងសរុប ១៨.៨០០ម៉ែត្រ, ជួសជុលផ្លូវបេតុង ប្រវែង ៤៣៧ម៉ែត្រ និងជួសជុលផ្លូវដីក្រួសក្រហម ចំនួន ២ខ្សែ ប្រវែងសរុប ៨.១៤៥ ម៉ែត្រ
- ដាក់លូមុខកាត់ ១ម៉ែត្រ ប្រវែង ១.៩១៤ម៉ែត្រ ក្នុងក្រុងពោធិ៍សាត់ និងដាក់លូទោល លូភ្លោះ មុខកាត់ ១ម៉ែត្រ កាត់ទទឹងផ្លូវ ២កន្លែង ចំនួន ៤០កង់ ក្នុងស្រុកក្រគរ
- ជួសជុលសួនច្បារក្បាលស្ពានថ្មផ្លូវជាតិលេខ៥ ចំនួន ៨.២២៤ម៉ែត្រការ៉េ, ជួសជុលប្រព័ន្ធបណ្តាញទឹកសួនច្បារ និងចាក់ដីបំពេញទីធ្លាក្នុងសាលាខេត្ត
- ស្ថាបនាជើងទេរច្រាំងស្ទឹងនៅស្រុកកណ្តៀង ប្រវែង ១៨,៧ម៉ែត្រ ជំរេល ៥,៥ម៉ែត្រ និងនៅក្រុងពោធិ៍សាត់ ប្រវែង ១៣៥,៧ម៉ែត្រ កម្ពស់ ៣,២ម៉ែត្រ រួមជាមួយការធ្វើបង់អង្គុយអមសួនច្បារ
- ស្ថាបនាទំនប់បង្វៀរក្បាលហុងស្ទឹងពោធិ៍សាត់ប្រវែង ៩៤ម៉ែត្រ ទទឹង ៤៦,៣៥ម៉ែត្រ កម្ពស់ ១,៣ម៉ែត្រ និងជញ្ជាំងទប់ដីច្រាំងស្ទឹង សរុបប្រវែង ២១៦,៦៥ម៉ែត្រ កម្ពស់ ៨,៤ម៉ែត្រ
- ស្ពានប្រឡាយចំនួន ១ខ្សែ ប្រវែង ៤៨៨ ម៉ែត្រ ស្ថិតនៅសង្កាត់លលកស ក្រុងពោធិ៍សាត់
- រៀបចំដាំបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈចំនួន ១៥១ដើម និងតបណ្តាញប្រវែង ៥.៨៨០ម៉ែត្រ សងខាងផ្លូវក្នុងក្រុងពោធិ៍សាត់។

## ២.២.ថវិកាមូលនិធិរដ្ឋបាលក្រុង ស្រុក

បានទទួលថវិកាអភិវឌ្ឍន៍ចំនួន **ដប់បីប៊ីលាន ប្រាំបួនរយកៅសិបប្រាំបីលាន បីរយម្ភៃប្រាំបួនពាន់ ប្រាំពីររយកៅសិបប្រាំរៀលគត់** ដើម្បីសាងសង់សមិទ្ធផលដូចខាងក្រោមៈ

- សាងសង់ផ្លូវបេតុង ១១ខ្សែ ប្រវែង ៤.១៣២ ម៉ែត្រ និងស្ពានបេតុង ១កន្លែង
- សាងសង់ផ្លូវក្រាលក្រួសក្រហម ប្រវែង ៦៣.៣៤៨ ម៉ែត្រ និងផ្លូវដីស ប្រវែង ៧.៣១០ ម៉ែត្រ
- ដាក់លូ ២៥កន្លែង, លូរំដោះទឹក ប្រវែង ៣.១៨៥ ម៉ែត្រ, លូជ្រុងមានទ្វារទឹក ១កន្លែង,ជីកស្រះ ៣កន្លែង
- ស្ពានប្រឡាយ ប្រវែង ៤៩៤ ម៉ែត្រ, ជួសជុលលូបង្ហូរទឹកស្អុយប្រវែង ៤១០ម៉ែត្រ
- ជួសជុលអគាររដ្ឋបាល ២កន្លែង, សាងសង់ខ្លោងទ្វាររដ្ឋបាលសាលាស្រុក ២កន្លែង, ជួសជុលរបងសាលាក្រុង ស្រុក ៣កន្លែង, ជួសជុលសាលប្រជុំ ៣កន្លែង, ជួសជុលសួនច្បារ ៣កន្លែង, ចាក់សាបបរិវេណសាលាស្រុក ទំហំ ២.០៤៨ ម៉ែត្រការ៉េ, ចាក់ដីបំពេញទីធ្លាសាលាក្រុង ស្រុក ទំហំ ២៩ហិកតា និង ១.២៦០ ម៉ែត្រការ៉េ, សាងសង់របាំងការពារជ្រាំងស្ទឹង ប្រវែង ១,៤៥០ ម៉ែត្រ, ជួសជុលបណ្តាញភ្លើងបំភ្លឺផ្លូវសាធារណៈ ប្រវែង ១០០ម៉ែត្រ, ជួសជុលបង្គោលភ្លើង ៣១៦ដើម, សាងសង់ចំណតរថយន្ត ១កន្លែង, ក្រាលការ៉ូឡូទីធ្លាសាលាស្រុក និងចិញ្ចើមផ្លូវ ទំហំ ៥០០ម៉ែត្រការ៉េ, ពង្រីកអគារតភ្ជាប់នឹងចំណតឡាន ចំនួន ២កន្លែង, ជួសជុលរោងឡាន ចំនួន ៣កន្លែង និងបន្ទប់ទឹក ចំនួន ៣បន្ទប់។

## ២.៣.ថវិកាមូលនិធិរដ្ឋបាលឃុំ សង្កាត់

ថវិកាសម្រាប់អភិវឌ្ឍន៍ក្នុងមូលដ្ឋានសរុបចំនួន **សាមសិបប្រាំពីរប៊ីលាន ប្រាំមួយរយម្ភៃប្រាំបីលាន ពីររយប្រាំពីរពាន់ ប្រាំរយកៅសិបប្រាំរៀលគត់** ក្នុងនោះសមិទ្ធផលមានដូចខាងក្រោម៖

- សាងសង់ផ្លូវបេតុងអាមេប្រវែង ១៣.៩៩៧ ម៉ែត្រ, ផ្លូវក្រាលក្រួសក្រហមប្រវែង ៨៥៨.៤៧១ ម៉ែត្រ និងផ្លូវលំដីសប្រវែង ២៩.៨២៥ ម៉ែត្រ
- ជីកស្រះបានចំនួន ២២កន្លែង, ស្ពារប្រឡាយប្រវែង ៣៨.៤០០ ម៉ែត្រ, សាងសង់លូ ១៥៦កន្លែង
- សាងសង់ស្ពានបេតុង ០៩កន្លែង និងសង់លូរំដោះទឹកប្រវែង ២.៨២១ ម៉ែត្រ
- ជួសជុលសាឡង់ (សាលារៀនបណ្តែតទឹក) បានចំនួន០៣
- សាងសង់ទំនប់បង្ហៀទឹកចំនួន ០១កន្លែង

## ៣.សមិទ្ធផលតាមវិស័យ

### ៣.១.កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖

ខេត្តពោធិ៍សាត់ មានផ្ទៃដីផលិតកម្មដំណាំស្រូវសរុបប្រមាណ **១៧៤.៤៨៥** ហិកតា ទទួលបានទិន្នផលជាមធ្យមប្រមាណ ៤តោនក្នុងមួយហិកតា។ ចំពោះតុល្យភាពស្បៀងរយៈពេល ៥ឆ្នាំ (២០១៨-២០២២) កន្លងមកនេះ ខេត្តពោធិ៍សាត់ សម្រេចបានបរិមាណផលស្រូវសរុបចំនួន **២.៩១០.៦៩៥** តោន និងក្រោយពីកាត់ចំណាយលើការប្រើប្រាស់ទុកពូជហូបចុក និងការបាត់បង់ផ្សេងៗ ខេត្តពោធិ៍សាត់នៅសល់ស្រូវសម្រាប់នាំចេញចំនួន **១.៩៩៣.៣៥៤**តោន ស្មើនឹងស្បៀងគិតជាអង្ករចំនួន **១.២៧៥.៧៤៦** តោន។

ក្រៅពីដំណាំស្រូវ ខេត្តពោធិ៍សាត់ ក៏មានសក្តានុពលលើ ការផលិតដំណាំបន្លែសុវត្ថិភាព ដំណាំរួមផ្សំ ដំណាំកសិ-ឧស្សាហកម្ម និងដំណាំរកប្រាក់ចំណូលផ្សេងៗផងដែរ (ដូចជាដំណាំបន្លែ ដំណាំពោតក្រហម ដំឡូងមី សណ្តែកបាយ សណ្តែកសៀង អំពៅ ល្ង ម្រេច កៅស៊ូ ទុរេន ស្វាយ ស្វាយចន្ទី និងជាពិសេសដំណាំក្រូចពោធិ៍សាត់) ហើយជាក់ស្តែងផ្ទៃដីដំណាំសាកវប្បកម្មសរុបប្រចាំឆ្នាំជាមធ្យមសរុបប្រមាណ ១.៥៧០ ហិកតា ដែលទទួលបានបរិមាណផលសរុប ១៩.៦៦២ តោន និងផ្ទៃដីដំណាំឈើហូបផ្លែចំនួន ១២.៣២៥ហិកតា ដែលទទួលបានបរិមាណផលប្រមាណ ២០៥.៧៧៥ តោន។ និងផ្ទៃដីសម្រាប់ដំណាំឧស្សាហកម្ម រយៈពេលវែង និងខ្លី សរុបចំនួន៤៩.៩៣៧ហិកតា ដែលទទួលបានបរិមាណផលសរុបប្រមាណ ៦៣៧.៦៦៤ តោនក្នុងមួយឆ្នាំ។ ចំពោះដំណាំទាំងនេះប្រជាកសិករដាំដុះសម្រាប់ផ្គត់ផ្គង់ក្នុងស្រុកនិងនាំចេញទៅលក់នៅបណ្តាខេត្តជិតខាង ។ រីឯដំណាំបន្លែវិញ ខេត្តពោធិ៍សាត់បាននិងកំពុងយកចិត្តទុកដាក់ជំរុញទៅលើការដាំដំណាំបន្លែសុវត្ថិភាព (ដែលក្នុងមួយថ្ងៃៗអាចផ្គត់ផ្គង់បានចំនួនពី១០តោន ទៅ១៥តោន) ដើម្បីធានាបានសន្តិសុខស្បៀងអាហាររូបត្ថម្ភ និងបង្កើនប្រាក់ចំណូលនៅតាមតំបន់ជនបទ។ បច្ចុប្បន្ននេះខេត្តពោធិ៍សាត់មានសហគមន៍កសិកម្ម ចំនួន ៦០សហគមន៍ និងក្រុមបណ្តុំកសិករធ្វើអាជីកម្មកសិកម្មចំនួន ៧៤បណ្តុំ បាននឹងកំពុងផលិត ផលិតផលកសិកម្មសុវត្ថិភាពសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងខេត្ត និងក្រៅខេត្ត។

### ៣.២.ធនធានទឹក និងឧតុនិយម

ក្នុងខេត្តពោធិ៍សាត់ មានប្រព័ន្ធធារាសាស្ត្រខ្នាតធំ មធ្យម និងតូចសរុបចំនួន **៥១ប្រព័ន្ធ**។ ប្រព័ន្ធធារាសាស្ត្រខ្នាតធំ មធ្យម និងតូច បាននឹងកំពុងដំណើរការសរុបចំនួន **៣៣ប្រព័ន្ធ** លើ **៥១ប្រព័ន្ធ** ក្នុងនោះមានសំណង់ធំៗកាត់ស្ទឹងចំនួន **៧កន្លែង** និងសំណង់សិល្បការ ចំនួន **៣៩០កន្លែង** ដែលមានខ្នាតធំចំនួន **៥កន្លែង** ខ្នាតមធ្យម ចំនួន **៣៩កន្លែង** ខ្នាតតូចចំនួន **៥កន្លែង** និងអាងស្តុកទឹកចំនួន **២កន្លែង** និងប្រឡាយមេ ចំនួន **៧ខ្សែ** ស្មើនឹងប្រវែង **៨១.០០០ម៉ែត្រ** និងប្រឡាយរងចំនួន **១៧២ខ្សែ** ស្មើនឹងប្រវែង **៩៦.០០០ម៉ែត្រ** និងប្រឡាយជើងក្អែបចំនួន **៨៦៣ខ្សែ** ស្មើនឹងប្រវែង **៧៣៩.៣៥០ម៉ែត្រ** ដែលអាចស្រោចស្រពរដូវវស្សាលើផ្ទៃដីចំនួន **៩៧.៧០១ ហិកតា** និងរដូវប្រាំងរួមដំណាំផ្សេងៗ លើផ្ទៃដីចំនួន **២០.០០០ ហិកតា** និងមានទំនប់អាងទី៣ និងទំនប់អាងទឹកទី៥...ដែលអាចផ្ទុកទឹកបានចំនួន **៥០ លានម៉ែត្រគូប** ដែលជាអាងស្តុកទឹកសម្រាប់ផ្គត់ផ្គង់ដល់ការស្រោចស្រព និងការប្រើប្រាស់តាមដងស្ទឹងពោធិ៍សាត់ ជាពិសេសសម្រាប់ស្រុកភ្នំក្រវាញ ស្រុកបាកាន ក្រុងពោធិ៍សាត់ និងស្រុកកណ្តៀង ខេត្តពោធិ៍សាត់។

### ៣.៣.អភិវឌ្ឍន៍ជនបទ

នៅក្នុងខេត្ត មានផ្លូវក្រាលក្រួសក្រហមចំនួន ៨៣ខ្សែ ប្រវែង ៣១២,៥០ គីឡូម៉ែត្រ, ផ្លូវលំដីសចំនួន ៣២៣ខ្សែ ប្រវែង ៣១០,៩៥ គីឡូម៉ែត្រ។ បានស្ថាបនាផ្លូវក្រាលកៅស៊ូចំនួន ១៥ខ្សែ ប្រវែង ២៧៩ គីឡូម៉ែត្រ និងសាងសង់ស្ពានបេតុងចំនួន ០៦កន្លែង ប្រវែង ១៧០ម៉ែត្រ សាងសង់ទំនប់បង្ហៀរទឹក ០២ កន្លែង ប្រវែង ១២០ម៉ែត្រ, សាងសង់លូប្រអប់ ០៣កន្លែង លូមូលចំនួន ១៨កន្លែង។ បានជួសជុល និងថែទាំផ្លូវក្រាលកៅស៊ូចំនួន ១៥ខ្សែ ប្រវែង ២១០,៥០ គីឡូម៉ែត្រ, ផ្លូវក្រាលក្រួសក្រហមមានចំនួន ៥៨ ខ្សែ ប្រវែង ៤៦៥,២៣ គីឡូម៉ែត្រ។ ចំពោះការងារទឹកស្អាត បានសាងសង់អណ្តូងស្នប់ចំនួន ៥៧២ អណ្តូង , ផ្តល់ពាងត្រងទឹកភ្លៀងចំណុះ ១.០០០លីត្រ ចំនួន ១៤.៣៥០ពាង, ផ្តល់ស្រះសហគមន៍ចំនួន ១៥ ស្រះ ទំហំ ៥០មx៥០ម ជម្រៅ៤ម៉ែត្រ ចំនួន ៨ស្រះ និងទំហំ ១០០មx១០០ម ជម្រៅ១០ម៉ែត្រ ចំនួន ៧ កន្លែង និងផ្តល់ធុងចម្រោះតាមគ្រួសាររងគ្រោះដោយសារទឹកជំនន់ទឹកភ្លៀងចំនួន ៧០០ធុង។ លើសពីនេះបានផ្តល់បង្គន់អនាម័យតាមខ្នងផ្ទះចំនួន ៧.១៥៩ បង្គន់ និងផ្តល់បង្គន់អនាម័យសាធារណៈតាមសាលារៀន ចំនួន ២៧បង្គន់។

-បច្ចុប្បន្នក្នុងខេត្តពោធិ៍សាត់ មានទឹកស្អាតសម្រាប់ប្រើប្រាស់ចំនួន ៨០% និងការងារអនាម័យចំនួន ៨២% ទូទាំងខេត្ត។

### ៣.៤.សាធារណការ និងដឹកជញ្ជូន

ខេត្តពោធិ៍សាត់មានបណ្តាញផ្លូវជាតិ និងផ្លូវខេត្តចំនួន **៥៥**ខ្សែ ប្រវែងសរុប **១.០៩៨,២៩** គីឡូម៉ែត្រ រួមមាន៖ ផ្លូវជាតិ១លេខ ចំនួន**១**ខ្សែ ប្រវែង **៨៦,៣០** គីឡូម៉ែត្រ ផ្លូវជាតិ២លេខ ចំនួន **៤**ខ្សែ ប្រវែង **៣០៤,៤៧** គីឡូម៉ែត្រ ផ្លូវខេត្តចំនួន **៥០**ខ្សែ ប្រវែង **៧០៧,៥២** គីឡូម៉ែត្រ និងស្ពានសរុបចំនួន **១៦៩**កន្លែង ប្រវែង **៤,៣៩** គីឡូម៉ែត្រ លូគ្រប់ប្រភេទប្រវែង **១០៨,៨០** គីឡូម៉ែត្រ។ ផ្លូវក្នុងក្រុងពោធិ៍សាត់មានចំនួន **៧៧**ខ្សែ ប្រវែង **៩៧,១០** គីឡូម៉ែត្រ (ក្រាលកៅស៊ូប្រវែង **៣៦,៩២** គីឡូម៉ែត្រ) និងលូគ្រប់ប្រភេទចំនួន **៤២,១៣** គីឡូម៉ែត្រ។

ចំពោះការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងរយៈពេល **៥ឆ្នាំ**កន្លងទៅ ខេត្តពោធិ៍សាត់សម្រេចបាន៖

- ស្ថាបនាផ្លូវជាតិលេខ៥ ឡើងវិញ ប្រវែងសរុប **៨៦,៣០** គីឡូម៉ែត្រ ដោយក្រាលបេតុងកៅស៊ូ (AC) សម្រេចបានលទ្ធផល **៨៩%** (គម្រោងកម្ចីពីរដ្ឋាភិបាលជប៉ុន)។
- ស្ថាបនាផ្លូវជាតិលេខ១០ (វាលវែង-អូរសោម) ប្រវែងសរុប **៩៦** គីឡូម៉ែត្រ ដោយក្រាលកៅស៊ូ DBST សម្រេចបានលទ្ធផល **៦៩%** (គម្រោងកម្ចីពីរដ្ឋាភិបាលចិន)។
- ស្ថាបនាផ្លូវជាតិ និងផ្លូវខេត្ត ដោយក្រាលកៅស៊ូ DBST បានប្រវែងសរុប **៣៤,៨០** គីឡូម៉ែត្រ
- ស្ថាបនាផ្លូវខេត្ត ដោយក្រាលដីល្បាយថ្ម បានប្រវែងសរុប **១២,១០** គីឡូម៉ែត្រ
- ស្ថាបនាស្ពានបេតុងបានប្រវែងសរុប **៧៨** ម៉ែត្រ
- ស្ថាបនាស្ពានបេឡេត៍បានប្រវែងសរុប **៦៣** ម៉ែត្រ
- ស្ថាបនាលូបណ្តោយផ្លូវជាតិ និងផ្លូវខេត្តបានប្រវែងសរុប **១៦.៩៧៦** ម៉ែត្រ
- ស្ថាបនាលូកាត់ទទឹងផ្លូវជាតិ និងផ្លូវខេត្តបានប្រវែងសរុប **២២២** ម៉ែត្រ
- ស្ថាបនាផ្លូវក្រាលកៅស៊ូ DBST និងបេតុងប្រវែងសរុប **២១,៨០** គីឡូម៉ែត្រ ប្រព័ន្ធលូរំដោះទឹកភ្លៀង-ទឹកកខ្វក់ប្រវែងសរុប **២៣,៧០** គីឡូម៉ែត្រ និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់មានសមត្ថភាព **២,៤០០** ម៉ែត្រគូបក្នុងមួយថ្ងៃក្នុងក្រុងពោធិ៍សាត់ សម្រេចបានលទ្ធផល **៩៩%** (គម្រោងរបស់ធនាគារអភិវឌ្ឍអាស៊ី ADB)។
- ស្ថាបនាទីលានចាក់សំរាមសម្រេចបានលទ្ធផល១០០%(គម្រោងរបស់ធនាគារអភិវឌ្ឍអាស៊ី ADB)។

## ៣.៥.ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ក្នុងរយៈពេល៥ឆ្នាំនេះ យើងមានរោងចក្រធុនធំ ចំនួន **១១មូលដ្ឋាន** និងសហគ្រាសធុនតូចមធ្យម ចំនួន **២៧៩មូលដ្ឋាន** និងមានអង្គភាពរដ្ឋាករទឹកដែលមានសមត្ថភាពផលិតទឹកបាន **៧.២០០** ម៉ែត្រគូបក្នុង១ថ្ងៃ សម្រាប់ធ្វើការផ្គត់ផ្គង់នៅក្នុងក្រុងចំនួន**០១** ស្រុកចំនួន**០២** សង្កាត់ចំនួន**០៧** ឃុំចំនួន **០៦** និងភូមិសរុបចំនួន **១២៩** ទូទាំងតំបន់សេវាស្មើនឹង **៥៦%** និងមានស្ថានីយទឹកស្អាតឯកជននៅតាមបណ្តាស្រុកសរុប **០៨មូលដ្ឋាន** មានសមត្ថភាព ផលិតទឹកបាន **១៤.៩៦៦** ម៉ែត្រគូបក្នុង១ថ្ងៃ។ បានផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ជូនបងប្អូនប្រជាពលរដ្ឋសរុប **២៤ឃុំ** មានភូមិសរុប **១៣៥**ភូមិ ស្មើនឹង **៣១,៨១%** នៃតំបន់សេវា និងឈានទៅរកការផ្គត់ផ្គង់ឱ្យបាន១០០% ទូទាំងតំបន់សេវាគ្របដណ្តប់នៅឆ្នាំ២០២៥។

## ៣.៦.រ៉ែ និងថាមពល

**វិស័យធនធានរ៉ែ៖** អាជីវកម្មធនធានរ៉ែមានចំនួន **៤៩**មូលដ្ឋាន រួមមាន៖ ខ្សាច់បូម ចំនួន **២៥**មូលដ្ឋាន, ខ្សាច់បក ចំនួន **១១**មូលដ្ឋាន, ដីក្រហម ដីស ចំនួន **១១**មូលដ្ឋាន, ថ្មសំណង់ ចំនួន **០១** មូលដ្ឋាន និងថ្មកែវ ចំនួន **០១**មូលដ្ឋាន។

**វិស័យថាមពល៖** ចំពោះវារីអគ្គិសនីមានចំនួន**០២** រួមមាន៖ វារីអគ្គិសនីស្ទឹងអាតៃ ស្ថិតនៅភូមិធាយលូក ឃុំអូរសោម ស្រុកវាលវែង មានអនុភាព **១២០**មេហ្គាវ៉ាត់(MW) កំពុងដំណើរការ និងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ស្ថិតនៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង មានអនុភាព **៨០**មេហ្គាវ៉ាត់ (MW) ក្រុមហ៊ុនកំពុងដំណើរការសាងសង់ទំនប់ ហើយគម្រោងនេះនឹងដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ ២០២៦ នាពេលខាងមុខនេះ។ ក្នុងខេត្តមានអនុស្ថានីយ ចំនួន**៣**៖ អនុស្ថានីយអូរសោម, អនុស្ថានីយពោធិ៍សាត់ និង អនុស្ថានីយស្វាយស។

+ថាមពលពន្លឺព្រះអាទិត្យ និងថាមពលផ្សេងៗ រួមមាន៖

- ស្ថានីយអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ មានអនុភាព **៩០**មេហ្គាវ៉ាត់(MW) ០១កន្លែង, មានអនុភាព **១០**គីឡូវ៉ាត់ម៉ោង(KWH) ០១កន្លែង, មានអនុភាព **០៧**គីឡូវ៉ាត់ម៉ោង (KWH) ០១កន្លែង និងស្ថានីយសាកអាគុយ ដើរដោយពន្លឺព្រះអាទិត្យ ថាមពលខ្យល់ និងប្រេងខ្មៅ មានអនុភាព **៥១៩** គីឡូវ៉ាត់ម៉ោង(KWH) ០១កន្លែង។
- មូលនិធិកម្មវិធីថាមពលអូស្ត្រាលី(ODA) សាងសង់ឡើងដោយ សាធារណៈរដ្ឋកូរ៉េ ចំនួន០៤ នៅស្រុកភ្នំក្រវាញ មានដូចជា៖ កម្លាំង **៣៤.៦**គីឡូវ៉ាត់ ១កន្លែង, កម្លាំង **១៣.៩** គីឡូវ៉ាត់ ១កន្លែង, កម្លាំង **៦.៩** គីឡូវ៉ាត់ ១កន្លែង និងកម្លាំង **១៣.៩** គីឡូវ៉ាត់ ១កន្លែង។

**ស្ថានីយប្រេងឥន្ធនៈ** ចំពោះ**ស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ** និង**ស្ថានីយរួមប្រេង** និង**ឧស្ម័ន ឥន្ធនៈ** មានចំនួន **១៨៤ទីតាំង** រួមមាន៖ ស្ថានីយប្រេងឥន្ធនៈមានចំនួន **១២៦**ទីតាំង, ស្ថានីយឧស្ម័នឥន្ធនៈមានចំនួន **០២**ទីតាំង, ស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈមានចំនួន **៣៤**ទីតាំង, ស្ថានីយប្រេងឥន្ធនៈ ពណ៌ក្រហមមានចំនួន **០៨**ទីតាំង និងស្ថានីយប្រេងឥន្ធនៈតូចៗមានចំនួន **១៤**ទីតាំង។

## ៣.៧.ពាណិជ្ជកម្ម

នៅក្នុងខេត្ត មានក្រុមហ៊ុន សហគ្រាស ពាណិជ្ជកម្មសរុបចំនួន **១.១៦២** ក្រុមហ៊ុន/សហគ្រាស ក្នុងនោះ៖ ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមាន **២៩២** ក្រុមហ៊ុន, សហគ្រាសឯកបុគ្គលមាន **៤៨២** សហគ្រាស និងសាខាក្រុមហ៊ុនមាន **៣៨៨** សាខា ហើយបានគ្រប់គ្រងទិន្នន័យស្ថិតិក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្ម និងអាជីវកម្មសរុបចំនួន **៦.៤១១** មូលដ្ឋាន។

លើសពីនេះ បានចុះតាមដានថ្លៃទំនិញ បរិមាណផ្គត់ផ្គង់ និងតម្រូវការលើមុខទំនិញប្រចាំថ្ងៃ ចំណែក ស្រូវ អង្ករ នៅតាមបណ្តារោងម៉ាស៊ីនកិនស្រូវសម្រាប់នាំចេញក្នុងស្រុក និងក្រៅស្រុកមានចំនួន **១០**កន្លែង ឡសម្ងួតសរុប **៦៣**ឡ ក្នុងនោះក៏មានឈ្មួញប្រមូលទិញស្រូវមកពីតាមបណ្តាខេត្តមួយចំនួន ដើម្បីនាំចេញទៅលក់នៅប្រទេសវៀតណាមផងដែរ។

ដើម្បីបន្តជំរុញការងារអភិវឌ្ឍពាណិជ្ជកម្ម និងស្វែងរកទីផ្សារ ខេត្តបានកៀរគរ កសិករ ពាណិជ្ជករ សហគមន៍បានចំនួន **១៤**ផលិតករ មានផលិតផលចំនួន **១០**មុខ រួមមាន៖ ក្រូចពោធិ៍សាត់ ចម្លាក់ថ្មកែវពោធិ៍សាត់ ស្ករត្នោត អំបុកអូតាប៉ោង បង្គីវល្លិ៍រំពាក់ សិប្បកម្មធ្វើពីដើមត្នោត ត្រីកែច្នៃ ត្រីងៀត គោងៀត បន្លែសុវត្ថិភាព និងពូជស្រូវសែនក្រអូប។ ក្រៅពីនេះផលិតផលដែលមានសក្តានុពលក្នុងខេត្តមួយចំនួនរួមមាន៖ ក្រូចពោធិ៍សាត់ ជំឡូងមី ពោតក្រហម ម្រេច ស្វាយកែវរមៀត មៀនប៉ៃលិន សិប្បកម្មចម្លាក់ថ្មកែវ សិប្បកម្មកែច្នៃពីដើមត្នោត និងសហគមន៍ស្ករត្នោត។

## ៣.៨.ទេសចរណ៍

ខេត្តពោធិ៍សាត់មានរមណីយដ្ឋានទេសចរណ៍ធម្មជាតិ តំបន់អេកូទេសចរណ៍ និងតំបន់ចម្ការហូបផ្លែនានា ដែលជួយជំរុញកំណើនសេដ្ឋកិច្ចដល់ប្រជាពលរដ្ឋក្នុងខេត្ត។ ក្នុងរយៈពេល៥ឆ្នាំនេះ មានភ្ញៀវទេសចរសរុបចំនួន **៣.៩១០.១៤៩**នាក់ ស្រី **២.០៣៣.២៧៤** នាក់ ក្នុងនោះ៖ ភ្ញៀវមកពីប្រទេសបារាំង ឈរលំដាប់លេខ១ និងភ្ញៀវទេសចរឈរលំដាប់បន្ទាប់រួមមាន៖ ចិន អូស្ត្រាលី អ៊ីតាលី ជប៉ុន និងអង់គ្លេសឈរលំដាប់បន្តបន្ទាប់។

នៅក្នុងខេត្តមានសណ្ឋាគារចំនួន ៥កន្លែង, ផ្ទះសំណាក់ឬផ្ទះមានបន្ទប់ជួល ឬស្នាក់នៅមានចំនួន ៦៩កន្លែង, ភោជនីយដ្ឋាន-អាហារដ្ឋានចំនួន ៦៨កន្លែង, ឌីស្កូតែកចំនួន ០១កន្លែង, ខារ៉ាអូខេ ២៣កន្លែង, ម៉ាស្សា ១០កន្លែង, កីឡាស្នូកឃ័រ ០២កន្លែង, រមណីយដ្ឋាន និងតំបន់ទេសចរណ៍មាន ៣៩កន្លែង ក្នុងនោះ (រមណីយដ្ឋានវប្បធម៌ ០៥កន្លែង, រមណីយដ្ឋានទេសចរណ៍កែច្នៃ ១១កន្លែង, រមណីយដ្ឋានទេសចរណ៍ធម្មជាតិ ០៩កន្លែង, សហគមន៍/អេកូ-ទេសចរណ៍ ១០កន្លែង និងកសិ-ទេសចរណ៍ ០៤កន្លែង)។ ទន្ទឹមនេះ ឯកឧត្តម ស៊ុយ សែម ប្រធានក្រុមការងារចុះជួយមូលដ្ឋានខេត្ត និងលោកជំទាវជា ខេង រួមជាមួយរដ្ឋបាលខេត្ត បានធ្វើការជួសជុល និងកែលម្អបុរីវប្បធម៌កោះសំពៅមាស ដាក់បង្គោលភ្លើងបំភ្លឺ ដងទង់ជាតិ និងកែលម្អផ្សេងទៀត ឲ្យកាន់តែមានភាពទាក់ទាញភ្ញៀវទេសចរណ៍ និងប្រជាពលរដ្ឋទូទៅ។

ផ្តើមចេញពីការខិតខំទាំងអស់ខាងលើនេះ ក្រុងពោធិ៍សាត់បានទទួលជ័យលាភីរង្វាន់ ២ទងក្នុងការងារប្រឡងប្រណាំងទីក្រុងស្អាត។

ចំពោះសក្តានុពល ខេត្តមានបឹងទន្លេសាបដែលអំណោយផលដល់ការវិនិយោគទេសចរណ៍ផ្លូវទឹក និងមានតំបន់ភ្នំដែលអំណោយផលដល់ការវិនិយោគទេសចរណ៍ធម្មជាតិ ជាពិសេសនៅស្រុកវាលវែងដែលមានស្ថានភាពជាតំបន់ខ្ពង់រាប និងជាតំបន់ភ្នំប្រកបដោយព្រៃឈើខៀវស្រងាត់ មានផ្ទៃទឹក បឹង ស្ទឹងជ្រលង ដងអូរ គួរឲ្យគយគន់ អាកាសធាតុត្រជាក់ ហើយមានលក្ខណៈភូមិសាស្ត្រពិសេស ដោយម្ខាងជាជម្រាលចុះទៅលម្ហសមុទ្រ និងម្ខាងទៀតជាជម្រាលចុះទៅលម្ហបឹងទន្លេសាប ធ្វើឲ្យបច្ចុប្បន្នបាននិងកំពុងចាប់ផ្តើមក្លាយជាទីចាប់អារម្មណ៍ពីភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិទៀតផង ដែលប៉ុន្មានទសវត្សមុនជាកន្លែងដែលញាំញីទៅដោយសង្គ្រាមគ្មានឯងដ៏គួរអោយភ័យខ្លាច។

## ៣.៩.ផែនការខេត្ត

នៅក្នុងខេត្តមានចំនួនគ្រួសារក្រីក្រសរុប **២៨.០៣៧** គ្រួសារ ក្នុងនោះ **ក្រ១** សរុប **១២.៥៤៣** គ្រួសារ និង**ក្រ២** សរុប **១៥.៤៩៤** គ្រួសារ និងចំនួនគ្រួសារងាយរងហានិភ័យសរុប **៨.៨០៨** គ្រួសារ ក្នុងនោះ គ្រួសារងាយរងហានិភ័យដោយអតិផរណាសរុប **៥.០៤៩** គ្រួសារ និងគ្រួសារងាយរងហានិភ័យដោយទឹកជំនន់សរុប **៣.៧៥៩** គ្រួសារ។

## ៣.១០.សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ដើម្បីដោះស្រាយរាល់កង្វះខាតរបស់បងប្អូនអតីតយុទ្ធជន គណៈកម្មាធិការសមាគមអតីតយុទ្ធជនកម្ពុជាខេត្ត បានចុះប្រគល់ថវិកាបេឡាមរណៈសង្គ្រោះ ចំនួន **៤៩៦** សព ថវិកាសរុប **មួយប៊ីលានប្រាំបួនរយប៉ែតសិបបួនលានរៀលគត់**, ចុះសួរសុខទុក្ខ និងនាំយកអំណោយជូនសមាជិកតាមគេហដ្ឋាន បានចុះប្រគល់ថវិកាធានារ៉ាប់រងសង្គម ជូនគ្រួសារសពអតីតយុទ្ធជនចំនួន **២៩៦** សព ថវិកាចំនួន **ពីរប៊ីលាន បីរយហុកសិបមួយលាន បីរយកៅសិបបួនពាន់ បីរយកៅសិបប្រាំមួយរៀលគត់** និងរៀបចំផ្តល់ដីនិងផ្ទះជូនបងប្អូនអតីតយុទ្ធជន និងគ្រួសារសរុបចំនួន **៦២៨** ខ្នងផ្ទះ សង់សាលារៀន មន្ទីរពេទ្យ និងបង្កើតសម្ព័ន្ធមេត្រីភាពរវាងមន្ទីរ អង្គភាពជំនាញ ជាមួយគ្រួសារអតីតយុទ្ធជន នៅភូមិប៊ុនរ៉ានីសែនជ័យ ដំណាក់ត្រយឹង ស្ថិតក្នុងឃុំព្រងិល ស្រុកភ្នំក្រវាញ។

ជាមួយនេះបានអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ដោយដំណើរការបើកប្រាក់ឧបត្ថម្ភជូនគ្រួសារក្រីក្រសរុបចំនួន **២៨.០៦០** គ្រួសារ។ ថវិកាដែលបានបើកផ្តល់ចាប់តាំងពីផ្តើមកម្មវិធីសរុបចំនួន **មួយរយហាសិបពីរប៊ីលាន មួយរយប៉ែតសិបលាន បីរយប៉ែតសិបពាន់រៀលគត់។**

ចំពោះការបើកប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម០២ឆ្នាំ ចាប់តាំងពីចាប់ផ្តើមកម្មវិធីដល់ឆ្នាំ២០២២ សរុប **៥.៣៣៧** នាក់ និងកុមារអាយុក្រោម ០២ឆ្នាំសរុប **១.៩០៧** នាក់ ចំណាយថវិកាសរុបចំនួន **បីប៊ីលាន កៅសិបប្រាំបួនលាន ប្រាំរយហុកសិបពាន់រៀលគត់។** បន្ថែមពីនេះ ក៏កំពុងដំណើរការបើកផ្តល់សាច់ប្រាក់ដល់គ្រួសារងាយរងហានិភ័យដោយទឹកជំនន់ និងគ្រួសារងាយរងហានិភ័យដោយសម្ពាធអតិផរណាសុរបចំនួន **៤.៧៣១** គ្រួសារ ចំណាយថវិកាសរុបចំនួន ប្រាំមួយរយសាមសិបប្រាំបួនលាន បីរយហាសិបបួនពាន់ មួយរយរៀលគត់។

ទន្ទឹមនេះបានយកចិត្តទុកដាក់ដោះស្រាយស្បៀង គ្រឿងឧបភោគ បរិភោគ និងសម្ភារប្រើប្រាស់ជូនប្រជាពលរដ្ឋដែលមានជីវភាពជួបការលំបាកចំនួន ១.៤៩២គ្រួសារ និងដោះស្រាយតាមរយៈ កាកបាទក្រហម សប្បុរសជន និងក្រុមការងារបានចំនួន ៣១.៦៩៤គ្រួសារ។

## ៣.១១.ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ខេត្តពោធិ៍សាត់ មានសហគ្រាស គ្រឹះស្ថានសរុបចំនួន ២០០ សហគ្រាស មានកម្មករ និយោជិតសរុបចំនួន ១១.២២៦ នាក់ស្រី ៧.៣៦៨នាក់ ក្នុងនោះ៖ មានរោងចក្រកាត់ដេរសម្លៀកបំពាក់ ក្រុមហ៊ុនរៀបចំគ្រឿងបង្គុំ និងដំឡើងរថយន្ត ហ្វត សម្រាប់ផ្គត់ផ្គង់ទីផ្សាររថយន្តក្នុងស្រុក, ក្រុមហ៊ុនព្រីសាយស៍ អេឡិកទ្រីកមេនូហ្វេកធីរី ដែលជារោងចក្រសម្រាប់ផលិតឧបករណ៍ត្រង់ស្វ័រ និងដំឡើងបរិក្ខាអគ្គិសនី និងក្រៅពីនោះជាក្រុមហ៊ុន រោងចក្រ សហគ្រាសចម្រុះ។

ទន្ទឹមនេះបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវវ័យបានចំនួន ៧.៥៧០នាក់ ស្រី ៣.៣៨៤នាក់ លើផ្នែកជួសជុលម៉ាស៊ីន និងគ្រឿងអេឡិចត្រូនិច ផ្នែកតុបតែង និងគ្រឿងសម្អាង ផ្នែកអគ្គិសនី ផ្នែកព័ត៌មានវិទ្យា...។ល។ ក្រោយការបណ្តុះបណ្តាលរួច អ្នកមានការងារធ្វើមានចំនួន ២.៧៤២នាក់ ស្មើ ៣៦,២២% នៃអ្នកដែលទទួលបានការបណ្តុះបណ្តាល។

## ៣.១២.សុខាភិបាល

ខេត្តពោធិ៍សាត់ មានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន **០៤**, មន្ទីរពេទ្យបង្អែកចំនួន **០៤**, មណ្ឌលសុខភាពចំនួន **៤៧** (កើន ៧កន្លែង), ប៉ុស្តិ៍សុខភាពចំនួន **០១** និងប៉ុស្តិ៍សុខភាពពន្ធនាគារចំនួន **០២**។ ក្រៅពីនោះយើងមានគ្លីនីកឯកជនចំនួន ៣៩០កន្លែង ដែលបាននិងកំពុងរួមចំណែកផ្តល់សេវាសុខាភិបាល។ ចំពោះសមិទ្ធផលសំខាន់ៗដែលសម្រេចបានដោយភ្នាក់ងារអនុវត្តន៍ នៅលើវិស័យសុខាភិបាល ចាប់ពីឆ្នាំ**២០១៨** ដល់ ឆ្នាំ**២០២២** រួមមាន៖

-ការផ្តល់សេវានៅមន្ទីរពេទ្យបង្អែកខេត្ត ចំពោះការពិគ្រោះជំងឺ (ករណីថ្មី) សរុបចំនួន **១.៤៩៥.៨៩៤** ករណី អត្រាប្រើប្រាស់គ្រែជាមធ្យមចំនួន **១០១%** រយៈពេលមធ្យមនៃការសម្រាកព្យាបាលចំនួន **០៥**ថ្ងៃ។

**-អំពីស្ថានភាព បង្ការ ទប់ស្កាត់ និងគ្រប់គ្រងជំងឺកូវីដ-១៩៖** មានមណ្ឌលចត្តាឡីស័ក សរុប **១៩ កន្លែង** សម្រាប់ទទួលពលករមកពីប្រទេសថៃបណ្តាប្រទេសផ្សេងៗ និងចំណូលស្រុក ដើម្បី ស្នាក់នៅ និងធ្វើ ចត្តាឡីស័កបានចំនួន **២១.៦៣៨** នាក់ (ស្រី **៩.៩៦២**នាក់)។ ការធ្វើតេស្តស្រាវជ្រាវរកជំងឺកូវីដ-១៩៖ បានចំនួនសរុប **៥២.៩៩៤** តេស្ត (ស្រី **២៦.១៩២**) និងមានករណី **វិជ្ជមាន** សរុប **៥.០៩៨** នាក់ (ស្រី **២.៩៥៧** នាក់) ដោយទទួលការព្យាបាលនៅតាមមណ្ឌលព្យាបាល ក្នុងនោះ បានជាសះស្បើយ សរុប **៥.០២១** នាក់ (ស្រី**២.៩១២**នាក់) មរណភាពចំនួន **៧៧** នាក់ (ស្រី**៤០**នាក់)។ ការព្យាបាលជំងឺកូវីដ-១៩ នៅតាមផ្ទះ និងសហគមន៍៖ មានអ្នកជំងឺសរុប **២.៩៩០**នាក់ (ស្រី **១.៦២១**នាក់),ជាសះស្បើយ ចំនួន **២.៩៧១**នាក់ (ស្រី **១.៦១៣**នាក់) និងមិនមានអ្នកទទួលមរណភាព។

**-អំពីស្ថានភាពនៃការផ្តល់ថ្នាំបង្ការប្រឆាំងនឹងជំងឺកូវីដ-១៩៖** គិតត្រឹមថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ ការផ្តល់ថ្នាំបង្ការសម្រេចបាន៖

+លើកទី១ សរុប ៤៤៤.៩២៧ នាក់ ស្រី ២២៣.០១៧ នាក់ = (៩៥.៦៨%)

+លើកទី២ សរុប ៤១៧.២២៩ នាក់ ស្រី ២១២.១៦១ នាក់ = (៩៣.៧៧%)

+លើកទី៣ សរុប ២៨៦.៦៩៨ នាក់ ស្រី ១៥៣.៥០៨ នាក់ = (៦៨.៧១%)

+លើកទី៤ សរុប ១២៨.៩៥០ នាក់ ស្រី ៧១.៧៩៥ នាក់ = (៤៤.៩៨%)

+លើកទី៥ សរុប ៣៩.៦៨៦ នាក់ ស្រី ២១.៣៥៧ នាក់ = (៣០.៧៨%)

+លើកទី៦ សរុប ៤.៣២៣ នាក់ ស្រី ១.៥៩០ នាក់ = (១០.៨៩%)

**-ការសាងសង់ និងសំណង់៖** ដោយមានការគាំទ្រធនធានថវិកាពីគម្រោងកូហ្វី (KOFIH-មូលនិធិកូរ៉េសម្រាប់ការថែទាំសុខភាពអន្តរជាតិ) និងប្រភពជំនួយផ្សេងៗមួយចំនួនទៀត ហេដ្ឋារចនាសម្ពន្ធ័សុខាភិបាលសាធារណៈមួយចំនួនរួមមាន៖ សាងសង់អគារសម្ភព និងថែទាំទារក ក្នុងមន្ទីរពេទ្យបង្អែកខេត្តចំនួន ០១ខ្នង,សាងសង់អគារមណ្ឌលចត្តាឡីស័ក នៅស្រុកកណ្តៀង និងស្រុកវាលវែង ចំនួន ០២ខ្នង, សាងសង់អគារថ្មី មណ្ឌលសុខភាពបណ្តែតទឹក ឃុំកំពង់លួងចំនួន ០១ខ្នង, សាងសង់ថ្មី និងពង្រីកទំហំបន្ទប់រង់ចាំសម្រាលចំនួន ០៧កន្លែង, ជួសជុល និងពង្រីកទំហំ មណ្ឌលសុខភាពចំនួន ១៥កន្លែង, សាងសង់ឡដុតសំរាមចំនួន ០៦កន្លែង, សាងសង់អគារថ្មី សម្រាប់មណ្ឌលសុខភាពថ្មីចំនួន ០៧ខ្នង, ជួសជុលអគារមណ្ឌលសុខភាព ស្រុកប្រតិបត្តិ និងឃ្លាំងឱសថចំនួន ០៨កន្លែង, ជួសជុលអគារផ្នែកជំងឺកុមារ នៃមន្ទីរពេទ្យបង្អែកខេត្តចំនួន ០១កន្លែង និងជួសជុលអគារសាលប្រជុំមន្ទីរសុខាភិបាលខេត្តចំនួន ០១កន្លែង។

ជាមួយនេះដើម្បីចូលរួមចំណែកក្នុងការងារមនុស្សធម៌ ក៏ដូចជាចូលរួមដោះស្រាយការលំបាកលើវិស័យសុខាភិបាល ឯកឧត្តម កែវ រតនៈ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គនាយកអគ្គិសនីកម្ពុជា និងរូបខ្ញុំបាទ បានផ្តួចផ្តើមកៀរគរមូលនិធិសប្បុរសជន កសាងអគារសង្គ្រោះបន្ទាន់ ១ខ្នង កម្ពស់៨ជាន់ ដោយបំពាក់សម្ភារទំនើប នៅមន្ទីរពេទ្យបង្អែកខេត្តនៅក្នុងឆ្នាំ២០២៣នេះ។

ក្នុងឆ្នាំ២០១៩ មន្ទីរពេទ្យបង្អែកស្រុកបាកាន បានទទួលជ័យលាភីចំណាត់ថ្នាក់លេខ១ទូទាំងប្រទេស"**ជាអង្គភាពផ្តល់សេវាសាធារណៈគំរូ**"។

## ៣.១៣.រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

ការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ បានបញ្ចូលទិន្នន័យក្បាលដី ចំនួន **១០៧.៨២៨** ក្បាលដី កំពុងបិទផ្សាយជាសាធារណៈចំនួន **៨២.១៦៨**ក្បាលដី និងបានចែកប័ណ្ណជូនប្រជាពលរដ្ឋចំនួន **៥៨.៣១០**ប័ណ្ណ ក្នុងនោះដីរដ្ឋដែលបានចុះបញ្ជីរួចមានចំនួន **១៤៤**ក្បាលដី។ គិតមកទល់ពេលនេះក្នុងក្របខណ្ឌទូទាំងខេត្តបានផ្តល់ប័ណ្ណជូនប្រជាពលរដ្ឋចំនួន **២០៦.៦២០**ក្បាលដី។

ការងារចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ(បំពេញបន្ថែម)បានចំនួន **៨៤៨**ប័ណ្ណ ។

ដោយមានការណែនាំពី ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋបាលខេត្តបានយកចិត្តទុកដាក់រៀបចំកែសម្រួលផ្ទៃដីតំបន់១ តំបន់២ តំបន់៣ នៃបឹងទន្លេសាប និងសហការរៀបចំកែសម្រួលព្រំនៃតំបន់ការពារធនធានធម្មជាតិ ដើម្បីផ្តល់សិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ អាស្រ័យផលជាក់ស្តែង និងពិតប្រាកដ ស្របតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ របស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី។

បានផ្តល់លិខិតអនុញ្ញាតសាងសង់សរុបចំនួន **២២០**គម្រោង សរុបទុនវិនិយោគសរុប ចំនួន **៣២.៥០៩.៨៧៦** ដុល្លារ (សាមសិបពីរលាន ប្រាំរយប្រាំបួនពាន់ ប្រាំបីរយចិតសិបប្រាំមួយដុល្លារគត់)។

រៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីក្រុងពោធិ៍សាត់ ដែលមកដល់ពេលនេះបានសម្រេចក្នុងក្របខណ្ឌនៃសេចក្តីព្រាងចុងក្រោយដោយរង់ចាំតែការសម្រេចជាផ្លូវការប៉ុណ្ណោះ។

បានរៀបចំផែនទីហេដ្ឋារចនាសម្ព័ន្ធរបស់ក្រុង ស្រុកទាំង៧ បានរួចរាល់។

បានរៀបចំផែនទីប្រើប្រាស់ដីធ្លីទាំង០៧ក្រុង/ស្រុក។

បានរៀបចំផែនទីបំបែករដ្ឋបាលស្រុកតាលោសែនជ័យ ដែលជាស្រុកថ្មីក្នុងខេត្តពោធិ៍សាត់។

កំពុងបន្តរៀបចំផែនទីភូមិ សម្រាប់គម្រោងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក្នុងភូមិ-ឃុំគោលដៅ។

## ៣.១៣.អប់រំ យុវជន និងកីឡា

- វិទ្យាល័យមានចំនួន ១៦កន្លែង (កើន ១កន្លែង) មានសិស្សសរុបចំនួន ៨.១៨៨នាក់ ក្នុងនោះស្រី ៤.២៣៨នាក់។
- អនុវិទ្យាល័យមានចំនួន ៤៤កន្លែង មានសិស្សសរុប ១៧,៨៩៨នាក់ ក្នុងនោះស្រី ៩.៣៩១នាក់។
- បឋមសិក្សាមានចំនួន ៣០១កន្លែង (កើន ០៥កន្លែង) មានសិស្សសរុប ៦៨.៤៨៦នាក់ ក្នុងនោះស្រី ៣៣.១៨០នាក់។
- មត្តេយសិក្សា ១៦៩កន្លែង (កើន ១៦កន្លែង) មានសិស្សសរុប ៧.៧៨៦នាក់ ក្នុងនោះកុមារី ៤.០១២នាក់។
- គ្រឹះស្ថានសិក្សាឯកជន មានចំនួន ១៣កន្លែង (កើន ៧កន្លែង)

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីគោរពរាប់អាន!**

ឆ្នាំ២០២៣នេះ ជាឆ្នាំចុងក្រោយនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងជាឆ្នាំដែលត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៃរដ្ឋសភា ហើយក៏ជាឆ្នាំដែលកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះ នៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេម លើកទី១២។ ដើម្បីសម្រេចបានការងារនេះ និងសម្រេចបានចក្ខុវិស័យ ដែលបានកំណត់ក្នុងផែនការអភិវឌ្ឍរបស់ខេត្ត រដ្ឋបាលខេត្តពោធិ៍សាត់មានទិសដៅការងារធំៗ សំខាន់ៗដូចខាងក្រោម៖

- ពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព
- ថែរក្សាសន្តិភាពឲ្យបានជាដាច់ខាត និងរក្សាសន្តិសុខសណ្តាប់ធ្នាប់ឲ្យបានល្អប្រសើរ
- សហការជាមួយអាជ្ញាធរបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការរៀបចំដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៃរដ្ឋសភា ឆ្នាំ២០២៣នេះ និងចាត់តាំងអនុវត្តវិធានការសន្តិសុខ ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅក្នុងបរិយាកាសសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានសុវត្ថិភាព
- ពង្រឹងការគ្រប់គ្រងជនបរទេសដែលស្នាក់នៅ ឬប្រកបអាជីវកម្មនៅក្នុងខេត្ត
- គ្រប់គ្រងព្រំដែនឲ្យបានល្អ ជំរុញកិច្ចសហប្រតិបត្តិការល្អជាមួយខេត្តត្រាត នៃព្រះរាជាណាចក្រថៃ ដើម្បីឲ្យព្រំដែននៃប្រទេសទាំង២ក្លាយទៅជាព្រំដែនមិត្តភាព សន្តិភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍ ពិសេសជំរុញការបើកច្រកទ្វារព្រំដែនអន្តរជាតិ ថ្មដា-បានថាសេន ជាផ្លូវការឲ្យបានឆាប់ និងធ្វើកិច្ចសហប្រតិបត្តិការវិស័យពាណិជ្ជកម្ម ទេសចរណ៍ សុខាភិបាល និងការងារ(ពលករ)
- កសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវ ថ្នល់ ស្ពាន លូ ប្រឡាយដោះទឹក និងសំណង់សិល្បការផ្សេងទៀតនៅតាមមូលដ្ឋាន
- កសាងស្តារប្រព័ន្ធធារាសាស្ត្រសំដៅធានាការស្រោចស្រព ដោយពង្រឹងការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទឹកឲ្យបានល្អ និងមានបរិយាបន្ន
- ជំរុញផលិតកម្មស្រូវ ដំណាំគ្រប់ប្រភេទ និងវារីវប្បកម្ម ដោយធ្វើការបណ្តុះបណ្តាលបច្ចេកទេសនៃការដាំដុះ និងការចិញ្ចឹម
- សហការ និងទំនាក់ទំនងល្អជាមួយក្រសួង ស្ថាប័ន សប្បុរសជន វិនិយោគិន និងដៃគូអភិវឌ្ឍនានាដើម្បីធ្វើការអភិវឌ្ឍមូលដ្ឋាន
- ថែរក្សា ការពារ និងគ្រប់គ្រងធនធានធម្មជាតិឲ្យបានល្អ
- ពង្រីកបណ្តាញអគ្គិសនី បណ្តាញទឹកស្អាតឲ្យមានលក្ខណៈគ្របដណ្តប់ដើម្បីទាក់ទាញការវិនិយោគ ពិសេសនៅស្រុកវាលវែងឲ្យក្លាយជាទីក្រុងទេសចរណ៍ ទីក្រុងសេដ្ឋកិច្ច និងទីក្រុងរដ្ឋបាលក្នុងក្របខណ្ឌសមាហរណកម្មខេត្តពោធិ៍សាត់ចូលទៅក្នុងប៉ូលសេដ្ឋកិច្ចទី៤ តាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល
- ជំរុញការចុះបញ្ជីដីធ្លី ទាំងដីរដ្ឋ និងដីប្រជាពលរដ្ឋសំដៅឲ្យសម្រេចតាមផែនការនៃការចុះបញ្ជីដីធ្លី

- ជំរុញបញ្ចប់ការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីក្រុងពោធិ៍សាត់ និងផែនការប្រើប្រាស់ដីនៅគ្រប់ឃុំក្នុងស្រុកវាលវែង
- ជំរុញការសាងសង់អាគារសង្គ្រោះបន្ទាន់ថ្មី ១ខ្នងនៅមន្ទីរពេទ្យបង្អែកខេត្ត និងបំពាក់សម្ភារៈបរិក្ខាទំនើបៗដែលជាមូលនិធិសប្បុរសធម៌ ព្រមទាំងពង្រឹងការផ្តល់សេវាសុខភាព នៅតាមមន្ទីរពេទ្យបង្អែកខេត្ត ស្រុក និងមណ្ឌលសុខភាព ប៉ុស្តិ៍សុខភាពជាដើម
- យកចិត្តទុកដាក់ផ្តល់សេវាជូនប្រជាពលរដ្ឋឲ្យកាន់តែល្អប្រសើរ ស្របតាមគោលការណ៍ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល
- យកចិត្តទុកដាក់ដោះស្រាយសំណើ សំណូមពរ និងវិវាទផ្សេងរបស់ប្រជាពលរដ្ឋតាមយន្តការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការឲ្យបានទាន់ពេលវេលាប្រកបដោយជំនឿជឿជាក់
- រៀបចំវេទិកាសាធារណៈនៅតាមភូមិនីមួយៗទូទាំងខេត្តដើម្បីស្វែងយល់ និងស្តាប់នូវបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន សំដៅធ្វើការដោះស្រាយ និងឆ្លើយតបឲ្យបានទាន់ពេលវេលា។

មុនបញ្ចប់សុន្ទរកថាស្វាគមន៍នេះ ខ្ញុំបាទសូមគោរពជូនពរ **ឯកឧត្តម ផៃ ស៊ីផាន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល** សូមទទួលបានជោគជ័យគ្រប់ភារកិច្ច និងសូមគោរពជូនពរលោកជំទាវ ឯកឧត្តម លោក លោកស្រី ទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ៖ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ៕

***សូមអរគុណ!***